ដើម្បីធានាថាសិស្សបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិត្រូវបានការពារពីអំពើហិង្សាផ្អែកយេនឌ័រនៅក្នុងសាលារៀន និងជំរុញលទ្ធភាពឱ្យកុមារបានចូលរួមដោយសមធម៌គ្រប់សកម្មភាពនៃជីវិតទាំងក្នុងសាលារៀន និងនៅតាមផ្ទះ គម្រោង **TIGER** នឹងសហការជាមួយ៖

- គណៈគ្រប់គ្រង និងសាស្ត្រាចារ្យនៅវិទ្យាស្ថានគរុកោសល្យ ដើម្បីដឹកនាំ និងបង្រៀននិស្សិតដោយគ្មានការប្រើប្រាស់អំពើហិង្សាផ្អែកយេនឌ័រ។
- គណៈគ្រប់គ្រង គ្រូបង្រៀននិងគណៈកម្មការទ្រទ្រង់សាលារៀនកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិចំនួន៤០ដើម្បីដឹកនាំ និងបង្រៀនសិស្សានុសិស្សដោយគ្មានការប្រើប្រាស់អំពើហិង្សាផ្អែកយេនឌ័រ និងបង្កើតបរិយាកាសសិក្សាល្អ និងមានសុវត្ថិភាព។
- អង្គការ និងសមាគមន៍ដែលគាំទ្រវិស័យអប់រំក្នុងខេត្តបាត់ដំបងចំនួន៥ ដើម្បីបំប៉នសមត្ថភាព និងគាំទ្រដល់សាលារៀនគោលដៅក្នុងការដឹកនាំ និងបង្រៀន ដោយគ្មានការប្រើប្រាស់អំពើហិង្សាផ្អែកយេនឌ័រ។
- មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ ដើម្បីពង្រឹងការយល់ដឹងអំពីតួនាទីយេនឌ័ររបស់ខ្លួន និងជួយបង្កើតឱ្យមានបរិយាកាសសមភាពយេនឌ័រចំពោះកូនៗរបស់ពួកគាត់។



គម្រោងនេះគឺជាកិច្ចសហប្រតិបត្តិការរវាង


អាសយដ្ឋានការិយាល័យគម្រោង **TIGER**
ផ្ទះលេខ B-53 ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុង-ខេត្តបាត់ដំបង
(បុរីពាណិជ្ជកម្មកណាឌីយ៉ា-អតីតបន្ទាយគុយហ្សេ)

លោកស្រី **ស៊ុន ម៉ាលី**
អ៊ីម៉ែល: tiger@vvob.be
លេខទូរស័ព្ទ: ០៩៩ ៦២៥ ៨៣០
www.vvob.be/cambodia/tiger




# គម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន TIGER

គម្រោង **TIGER** នឹងគាំទ្រវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង សាលាបឋមសិក្សា និងអនុវិទ្យាល័យចំនួន៤០ ឲ្យក្លាយជាសាលាគំរូ ដែលឆ្លើយតបយ៉ាងប្រសើរលើបញ្ហាយេនឌ័រ ដែលផ្តល់នូវបរិយាកាសល្អ និងមានសុវត្ថិភាពក្នុងការបង្រៀន និងរៀន។

With the support of THE BELGIAN DEVELOPMENT COOPERATION

Flanders State of the Art



## ២០១៨

ផលិតឯកសារណែនាំ (Action Guide) ស្តីពីការឆ្លើយតបនឹងសមភាពយេនឌ័រ សម្រាប់សាលារៀន

បង្កើតកម្មវិធី (app) សម្រាប់ទាញរឿងនិងប្រមូលទិន្នន័យ

អនុវត្តសាកល្បងឯកសារណែនាំនៅតាមសាលារៀនគោលដៅ

## ២០១៩

បំប៉ននិងណែនាំបន្ថែមដល់គណៈគ្រប់គ្រង និងសាស្ត្រាចារ្យនៅវិទ្យាស្ថានគរុកោសល្យ អំពីរបៀបដឹកនាំ និងបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ

## ២០១៩

បំប៉ន និងណែនាំបន្ថែមដល់គណៈគ្រប់គ្រង គ្រូបង្រៀន និងគណៈកម្មការទ្រទ្រង់សាលារៀន ចំនួន ២០ (ជំហានសាកល្បង) អំពីរបៀបដឹកនាំ និងបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ

បំប៉នបុគ្គលិកមន្ទីរ និងការិយាល័យ អ.យ.ក អំពីរបៀបធ្វើផែនការសកម្មភាព និងថវិកាសម្រាប់ឆ្លើយតបយេនឌ័រ

ប្រែក្លាយវិទ្យាស្ថានគរុកោសល្យឱ្យក្លាយជាគ្រឹះស្ថានគំរូដែលមានការឆ្លើយតបយ៉ាងប្រសើរលើបញ្ហា យេនឌ័រ

ចែករំលែកការបទពិសោធល្អៗជាមួយអ្នកពាក់ព័ន្ធផ្សេងៗទៀត

កែលម្អឯកសារណែនាំជាលើកចុងក្រោយ បន្ទាប់ពីអនុវត្តសាកល្បងនៅវិទ្យាស្ថានគរុកោសល្យ និងសាលារៀនចំនួន២០

បំប៉នបុគ្គលិកអង្គការសមាគមន៍ចំនួន៥ ឱ្យក្លាយជាគ្រូបង្គោល សម្រាប់បំប៉នបន្តដល់សាលារៀនគោលដៅ



## ២០២០

រៀបចំឱ្យមានសកម្មភាពរៀនសូត្រ និងឆ្លុះបញ្ចាំងពីគ្នាទៅវិញទៅមក រវាងវិទ្យាស្ថានគរុកោសល្យ និងសាលាសាកល្បងចំនួន២០

ធ្វើយុទ្ធនាការផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើហិង្សាផ្អែកយេនឌ័រតាមសាលារៀន

## ២០២០

បំប៉ន និងណែនាំបន្ថែមដល់គណៈគ្រប់គ្រង គ្រូបង្រៀន និងគណៈកម្មការទ្រទ្រង់សាលារៀន ចំនួន ២០ បន្ថែមទៀត អំពីរបៀបដឹកនាំ និងបង្រៀនដែលឆ្លើយតប នឹងសមភាពយេនឌ័រ

ចែករំលែកបទពិសោធន៍ល្អៗជាមួយអ្នកពាក់ព័ន្ធផ្សេងៗទៀត

ប្រែក្លាយសាលារៀនចំនួន៤០ឱ្យក្លាយជាសាលារៀនគំរូ ដែលមានការឆ្លើយតបយ៉ាងប្រសើរលើបញ្ហាយេនឌ័រ



## ២០២១

ផ្សព្វផ្សាយ និងចែកចាយឯកសារណែនាំ និងសម្ភារៈអប់រំ

ធ្វើយុទ្ធនាការផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើហិង្សាផ្អែកយេនឌ័រតាមសាលារៀន